**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០៧៥ សហវ.ប្រក

# ប្រកាស

## ស្ដីពីការបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្ដីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្ដីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារនិងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- បានឃើញសេចក្តីសម្រេចលេខ០០៣/១១ ល.ស អ.ប.ព ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីទម្រង់បែបបទនិងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១.~** ត្រូវបានបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. | ឯកឧត្តម **វង្សី វិស្សុត** អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | លោក **យក់ ម៉ុនណា** ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធានប្រចាំការ |
| ៤. | លោក **ហ៊ីវ សុវណ្ណា** អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៥. | លោក **ឡាយ ឫទ្ធី** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៦. | លោក **គីម សុភ:** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧. | លោក **សុខ សារាវុឌ្ឍ** ប្រធាននាយកដ្ឋានថវិកា | សមាជិក |
| ៨. | លោក **ឈឹម សារ៉េត** ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ៩. | លោក **អៀវ ស៊ុនលី** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| ១០. | លោក **ចាន់ សុធី** ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | សមាជិក |
| ១១. | លោក **ជា វុធណា** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | លេខាធិការ |

**ប្រការ២.~** ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលការងារអប់រំ ផ្សព្វផ្សាយ ច្បាប់ លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ធ្វើបញ្ជីសមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល ដើម្បីផ្ញើទៅអង្គភាពប្រឆាំងអំពើពុករលួយ
- ជួយសម្របសម្រួលឱ្យការងារប្រកាសទ្រព្យសម្បត្តិ និង បំណុល ដំណើរការបានត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេល
- ធ្វើជាសេនាធិការឱ្យប្រធានស្ថាប័នក្នុងការកសាងផែនការសកម្មភាពបង្ការ ទប់ស្កាត់អំពើពុករលួយ កសាងអង្គភាពសស្អាត និងលើកសរសើរ ព្រមទាំងការដាក់ពិន័យ កសាង និងពង្រឹងក្រមសីលធម៌ ព្រមទាំងបទប្បញ្ញត្តិនៃការទទួលអំណោយ
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលអនុវត្តសកម្មការងារជូនប្រធានស្ថាប័ន ពិនិត្យ សម្រេចដើម្បី ផ្ញើជូនអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ៣.~** ក្រុមជនបង្គោលខាងលើ អាចបង្កើតអនុក្រុមការងារផ្អែកតាមភាពចាំបាច់ដើម្បីជួយដល់ការបំពេញមុខនាទីរបស់ខ្លួន។

**ប្រការ៤.~** ប្រធានក្រុមជនបង្គោល អាចសម្រេចកោះប្រជុំក្រុមជនបង្គោលផ្អែកតាមភាពចាំបាច់។

**ប្រការ៥.~** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង
- «ដើម្បីជូនជ្រាប»
- សាមីខ្លួនក្នុងប្រការ ១ ដើម្បីអនុវត្ត
- ឯកសារ- កាលប្បវត្តិ